សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន
CAMBODIANS FOR RESOURCE REVENUE TRANSPARENCY

# សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន

លេខទី ០៥
ខែកញ្ញា ឆ្នាំ២០១០



រូបថត: កន្លែងធ្វើអាជីវកម្មរ៉ែដែលបានបោះបង់ចោលនៅខេត្តមណ្ឌលគិរី

## ច្បាប់ថ្មីរបស់អាមេរិកអាចជា "ជោគជ័យដ៏ធំធេងមួយ" ចំពោះតម្លាភាព

*ដោយ Frank Yetter បុគ្គលិក ស៊ីអារអាធី*

*ប្រភពមួយចំនួនដកស្រង់ពី Wire service reports*

បញ្ញត្តិដែលបានចុះហត្ថលេខាចូលជាច្បាប់ធរមានកាលពីខែសីហា ដោយលោកប្រធានាធិបតី Barack Obama ត្រូវបានសាទរពីសំណាក់សមាជិកសង្គមស៊ីវិលថា ជាជំហានដែលមានសារៈសំខាន់ក្នុងការឆ្ពោះទៅរកតម្លាភាព ដើម្បីធ្វើឱ្យប្រសើរឡើងក្នុងការរាយការណ៍ពីប្រាក់ដែលបានបង់របស់ក្រុមហ៊ុនសាធារណៈទាំងឡាយ ទៅប្រទេសទាំងឡាយណាដែលខ្លួនធ្វើប្រតិបត្តិការក្រៅពីសហរដ្ឋអាមេរិក។

ច្បាប់នេះត្រូវបានអនុម័តដោយគណៈកម្មាធិការព្រឹទ្ធសភាអាមេរិក ដែលដឹកនាំដោយព្រឹទ្ធសមាជិក លោក Christopher Dodd (D-Conn.) និងតំណាងលោក Barney Frank (D-Mass.) បង្កើតនូវបញ្ញត្តិថ្មីក្នុងការផ្តល់ប្រាក់កម្ចីដល់អតិថិជន និងវិស័យធនាគារ ដោយបន្ថែមទៅលើតម្រូវការថ្មីដែលទាមទារឱ្យក្រុមហ៊ុនធ្វើការដាក់បង្ហាញនូវព័ត៌មាននៃការបង់ប្រាក់ដែលផ្តល់ទៅឱ្យរដ្ឋាភិបាលនានាក្រៅពីសហរដ្ឋអាមេរិក។

វិធានការណ៍នេះ មានការសាទរជាខ្លាំងដោយអង្គការក្រៅរដ្ឋាភិបាលនៅកម្ពុជា ដែលធ្វើការជាមួយរដ្ឋាភិបាល ដើម្បីរៀបចំគោលនយោបាយឱ្យមានតម្លាភាពឱ្យកាន់តែប្រសើរឡើង រួមទាំងសម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន (ស៊ីអារអាធី)។

លោក ម៉ម សម្បត្តិ ប្រធានក្រុមប្រឹក្សាភិបាលសម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន បានមានប្រសាសន៍ថា "យើងជឿជាក់ថាការបើកចំហនូវរាល់ព័ត៌មានពីក្រុមហ៊ុនប្រេង ឧស្ម័ន និងរ៉ែ នឹងអាចឱ្យយើងទទួលបានព័ត៌មានពីចំណូលធនធាន និងផ្តល់អំណាចឱ្យយើងក្នុងការធ្វើឱ្យរដ្ឋាភិបាលមានការទទួលខុសត្រូវខ្ពស់ ដើម្បីប្រើប្រាស់ចំណូលធនធានពីប្រេងសម្រាប់អភិវឌ្ឍសេដ្ឋកិច្ច និងផ្តល់សេវាកម្មមូលដ្ឋាន ដូចជា ការអប់រំ និងការថែទាំសុខភាពជាដើម"។

លោក George Soros ប្រធានក្រុមប្រឹក្សាភិបាលនៃមូលនិធិ FiSoros និងជាអ្នកបង្កើតវិទ្យាស្ថានសង្គមបើកទូលាយ បានមានប្រសាសន៍ថា "វិធានការណ៍របស់ព្រឹទ្ធសភានេះ គឺជាជោគជ័យដ៏ធំធេងមួយ សម្រាប់សហរដ្ឋអាមេរិក សម្រាប់ប្រជាពលរដ្ឋនៅប្រទេសទាំងឡាយ ដែលមានធនធាន រ៉ែ ប្រេង ឬ ឧស្ម័ន និងសម្រាប់អ្នកវិនិយោគ និងប្រជាជនដែលទទួលស្គាល់តម្លាភាពហិរញ្ញវត្ថុនោះ គឺមានសារៈ-

តទៅទំព័រទី ២

## ទស្សនវិស័យ

ទស្សនវិស័យរបស់ CRRT គឺភោគទ្រព្យដែលបានមកពីឧស្សាហកម្មនិស្សារណកម្ម ត្រូវមានការគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវ ផ្នែកសង្គមដែលមានតម្លាភាព គណនេយ្យភាព និងការចូលរួមដើម្បីធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ទទួលបានផលចំណេញប្រកបដោយសមធម៌។

## គោលការណ៍របស់ អ៊ីអាយធីអាយ (EITI)

គោលការណ៍របស់ អ៊ីអាយធីអាយ (EITI) ត្រូវបានធ្វើការព្រមព្រៀងកាលពីឆ្នាំ ២០០៣ ដែលជាគ្រឹះដ៏សំខាន់របស់ការផ្តួចផ្តើមគំនិតនេះ។ គោលការណ៍ទាំងនោះមានដូចជា:

១. យើងជឿជាក់ថា ការប្រើប្រាស់ធនធានធម្មជាតិដោយប្រុងប្រយ័ត្ន គួរតែជាយន្តការដ៏សំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ដែលជួយឱ្យមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងកាត់បន្ថយភាពក្រីក្រ ក៏ប៉ុន្តែប្រសិនបើគ្រប់គ្រងមិនបានត្រឹមត្រូវនោះទេ វានឹងអាចផ្តល់ផលប៉ះពាល់ជាអវិជ្ជមាន ទាំងផ្នែកសេដ្ឋកិច្ច និងសង្គម។

២. យើងសូមធានាអះអាងថា ការគ្រប់គ្រងធនធានធម្មជាតិសម្រាប់ផ្តល់គុណប្រយោជន៍ដល់ប្រជាជននៅក្នុងប្រទេស គឺជាកម្មសិទ្ធិនៃអធិបតេយ្យភាពរបស់រដ្ឋាភិបាលក្នុងការអនុវត្តសម្រាប់សារប្រយោជន៍ក្នុងការអភិវឌ្ឍប្រទេសជាតិរបស់ពួកគេ។

តទៅទំព័រទី ២

## មាតិកា

- ច្បាប់ថ្មីរបស់អាមេរិក (ត) ............ ២
- គោលការណ៍របស់ EITI (ត) ............ ២
- ព័ត៌មានសង្ខេប ............ ៣
- តម្លាភាពមានភាពកើនឡើង ............ ៤
- ធ្វើការដើម្បីធានាបានពរជ័យ ............ ៦
- អភិបាលកិច្ចក្នុងវិស័យរ៉ែ ............ ៦

តមកពីទំព័រទី ១

## ច្បាប់ថ្មីរបស់អាមេរិកអាចជា...

សំខាន់ដើម្បីធ្វើឱ្យរាជរដ្ឋាភិបាល និងអាជីវកម្មមានការទទួលខុសត្រូវ"។

Ridaya Laodengkowe អ្នកសម្របសម្រួលថ្នាក់ជាតិនៃ Publish What You Pay ក្នុងប្រទេសឥណ្ឌូនេស៊ី បានលើកឡើងនៅក្នុងសន្និសីទសារព័ត៌មាននៅទីក្រុង Jakarta ថា "ច្បាប់នេះនឹងតម្រូវឱ្យក្រុមហ៊ុនប្រេង ឧស្ម័ន និងរ៉ែ ដែលបានចុះបញ្ជីក្នុងទីផ្សារភាគហ៊ុន និងគណៈកម្មការមូលប័ត្រសហរដ្ឋអាមេរិក ត្រូវតែផ្សព្វផ្សាយប្រាក់ចំណូលការបង់ពន្ធ និងសួយសារអាករផ្សេងៗរបស់ពួកគេទៅប្រទេសសាមី និងរដ្ឋាភិបាលរបស់អាមេរិក"។

Diarmid O'Sullivan ដែលជាអ្នកធ្វើយុទ្ធនាការរបស់អង្គការ Global Witness នៃក្រុមប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ បាននិយាយថា ច្បាប់នេះ "ពិតជាអស្ចារ្យ" និងប្រសិនបើអនុវត្តបានត្រឹមត្រូវ វាអាចជួយដល់ក្រុមហ៊ុនរ៉ែបញ្ឈប់ការស្ដីបន្ទោស ពីពលរដ្ឋចំពោះការប្រព្រឹត្តអំពើពុករលួយ។

លោក Raymond C. Offenheiser ប្រធានអង្គការអុកស្វាមអាមេរិក បានមានប្រសាសន៍ថា "ព្រឹទ្ធសភាបានធ្វើការប្ដេជ្ញា ដែលទឹកស្អាតមិនដល់អំពីតម្លាភាពហិរញ្ញវត្ថុ និងអភិបាលកិច្ចល្អក្នុងវិស័យមួយ ដែលមិនត្រឹមតែមានឥទ្ធិពលលើចំណូលពលរដ្ឋអាមេរិក ប៉ុន្តែថែមទាំងលើសហគមន៍ដែលងាយរងគ្រោះមួយចំនួននៅជុំវិញពិភពលោកផងដែរ"។

ច្បាប់នេះ ដែលនឹងយកទៅអនុវត្តលើសាជីវកម្មអាមេរិក និងសាជីវកម្មអន្តរជាតិ ក៏ផ្ដោតទៅលើការបង់ប្រាក់ដែលទាក់ទងនឹងប្រាក់រង្វាន់ ថ្លៃអាជ្ញាប័ណ្ណ និងចំណែករបស់រដ្ឋាភិបាលទទួលបានយោងទៅតាមកិច្ចព្រមព្រៀងបែងចែកផលិតផលផងដែរ។វាបានធ្វើជាគំរូខ្នាតស្ដង់ដារស្ម័គ្រចិត្តអន្តរជាតិនៃគំនិតផ្ដួចផ្ដើមតម្លាភាពឧស្សាហកម្មនិស្សារណកម្មដែលមានរដ្ឋាភិបាលក្រុមហ៊ុនប្រេង និងក្រុមអ្នកចាប់អារម្មណ៍ផ្សេងៗទៀត។

លោក ម៉ម សម្បត្តិ បានមានប្រសាសន៍ថា "ក្រៅពីបង្កើតបរិយាកាសល្អរវាងក្រុមហ៊ុន ស៊ីអាអាធី ជឿជាក់ថា ការផ្សព្វផ្សាយព័ត៌មានចំណូលទាំងនេះ គឺជាមធ្យោបាយល្អបំផុតដើម្បីជួយពង្រឹកអភិបាលកិច្ចល្អ និងជាពិសេសជួយរដ្ឋាភិបាល ដើម្បីការពារនិងទប់ស្កាត់អំពើពុករលួយ និងជួយពង្រឹងការគ្រប់គ្រងចំណូល"។

"បន្ថែមលើនេះ សុវត្ថិភាពថាមពលតាមរយៈច្បាប់តម្លាភាព នឹងបង្កើតស្ដង់ដារពិភពលោកថ្មីមួយដើម្បីឱ្យក្រុមហ៊ុនបើកទូលាយនូវរាល់ព័ត៌មានហិរញ្ញវត្ថុ។

ច្បាប់នេះវាមានតម្លៃគួរឱ្យគត់សំគាល់ថា នឹងផ្ដល់អំណាចឱ្យអ្នកវិនិយោគ និងអាចបង្កើនការវិនិយោគនៅប្រទេសកម្ពុជា ដោយសារថាអ្នកវិនិយោគបរទេស បានទទួលនូវទិដ្ឋភាពវិនិយោគពេញលេញ។

ទោះជាយ៉ាងណា មិនមែនសុទ្ធតែការឆ្លើយតបទៅលើច្បាប់ថ្មីនេះមានភាពវិជ្ជមាននោះទេ។

ពាណិជ្ជកម្មតុមូលអាមេរិក និងស្ថាប័នប្រេងអាមេរិក (API) ទាំងពីរនេះ បានជំទាស់ទៅលើបញ្ញត្តិនេះ ដោយនិយាយថា វិធាននេះទូលំទូលាយ និងស្មុគស្មាញពេក ដែលធ្វើឱ្យក្រុមហ៊ុនពាណិជ្ជកម្មសាធារណៈនៅក្នុងវិស័យឧស្សាហកម្មនិស្សារណកម្មមានលក្ខណៈប្រកួតប្រជែងមិនស្មើគ្នា។

អ្នកនាំពាក្យ API Misty McGowen បានមានប្រសាសន៍ថា "បញ្ញត្តិនេះ នឹងមិនបានគ្របដណ្ដប់ទៅលើការបង់ថ្លៃ ដែលធ្វើឡើងដោយក្រុមហ៊ុនប្រេងជាតិពីបណ្ដាប្រទេសនានា និងកំរិតភាពពិស្ដារដែលតម្រូវឱ្យរាយការណ៍ ធ្វើឱ្យដៃគូប្រកួតប្រជែងទទួលបានព័ត៌មានជាកម្មសិទ្ធិសំខាន់ៗនៅពេលដែលចង់ធ្វើការដេញថ្លៃ ដែលពួកគេនឹងអាចប្រើប្រាស់ព័ត៌មានទាំងនេះ ជាប្រយោជន៍របស់ពួកគេក្នុងការចរចាកិច្ចសន្យា"។

យ៉ាងណាមិញ ច្បាប់នេះ ហាក់បីដូចជាផ្ដោតទៅលើការបើកចំហរព័ត៌មាន និងតម្លាភាពដែលជាគោលការណ៍ណែនាំចាប់បង្ខំមួយទៅលើសិរិយាបថសាជីវកម្ម។

"វាជាការពិតប្រហែល ៦០% នៃផលិតកម្មប្រេងជាតិ គឺមានការចូលរួមពីក្រុមហ៊ុន ដែលចុះឈ្មោះក្នុងទីផ្សារភាគហ៊ុនអាមេរិក ការអនុវត្តកំណែទម្រង់លើ Dodd-Frank Wall Street Reform និងច្បាប់ការពារអ្នកប្រើប្រាស់ នឹងមានឥទ្ធិពលលើតម្លាភាពនៅក្នុងការធ្វើពាណិជ្ជកម្មនៅប្រទេសឥណ្ឌូណេស៊ី" នេះបើតាមការលើកឡើងរបស់លោក Ridaya Laodengkowe។

លោក បានមានប្រសាសន៍បន្ថែមថា "ក្រុមហ៊ុនប្រេង និងឧស្ម័នធំៗ ដែលប្រតិបត្តិការនៅប្រទេសឥណ្ឌូនេស៊ី ដូចជា Chevron Texaco, Total, Conoco Philips, Talisman, ExxonMobil, Royal Dutch Shell និង British Petroleum នឹងត្រូវគ្រប់គ្រងដោយច្បាប់នេះ"។/

តមកពីទំព័រទី ១

## គោលការណ៍របស់ អ៊ីអាយធីអាយ...

៣. យើងទទួលស្គាល់ថា គុណប្រយោជន៍នៃការទាញយកធនធានធម្មជាតិត្រូវបានធ្វើឡើងប្រៀបបានទៅនឹងលំហូរនៃប្រាក់ចំណូលក្នុងរយៈពេលជាច្រើនឆ្នាំ ហើយអាចមានតម្លៃខ្ពស់។

៤. យើងទទួលស្គាល់ថា ការយល់ដឹងរបស់សាធារណជនទៅលើប្រាក់ចំណូល និងចំណាយរបស់រដ្ឋាភិបាល អាចជួយឱ្យសាធារណជនធ្វើការពិភាក្សា និងផ្ដល់ដំណឹងអំពីជម្រើសដ៏ត្រឹមត្រូវ និងជម្រើសដ៏ជាក់លាក់ជាច្រើន សម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

៥. យើងបានគូសបញ្ជាក់អំពីសារៈសំខាន់នៃតម្លាភាពរបស់រដ្ឋាភិបាល និងក្រុមហ៊ុនឯកជននៅក្នុងវិស័យឧស្សាហកម្មនិស្សារណកម្ម និងតម្រូវការក្នុងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងតម្លាភាព។

៦. យើងទទួលស្គាល់ថា សមិទ្ធផលនៃតម្លាភាពត្រូវតែធ្វើឡើងក្នុងបរិបទគោរពកិច្ចសន្យា និងច្បាប់។

៧. យើងទទួលស្គាល់ថា ការលើកស្ទួយបរិយាកាសវិនិយោគទាំងក្នុងស្រុក និងក្រៅប្រទេស គឺគួរតែមានតម្លាភាព។

៨. យើងជឿជាក់លើគោលការណ៍ និងការអនុវត្តគណនេយ្យភាពដោយរដ្ឋាភិបាល ដើម្បីប្រជាពលរដ្ឋទូទៅជាម្ចាស់ទ្រព្យសម្បត្តិនៃលំហូរប្រាក់ចំណូល និងចំណាយ។

៩. យើងប្ដេជ្ញាចិត្តលើកស្ទួយឱ្យមានបទដ្ឋានខ្ពស់ ក្នុងការប្រតិបត្តិតម្លាភាព និងគណនេយ្យភាពនៃការរស់នៅជាទូទៅ នៅក្នុងជួររដ្ឋាភិបាល និងនៅក្នុងការធ្វើជំនួញផ្សេងៗ។

១០. យើងជឿជាក់ថាភាពស៊ីសង្វាក់គ្នាជាសកល និងការដែលអាចបញ្ចេញព័ត៌មានពីការចំណាយ និងចំណូល គឺជាការចាំបាច់ដែលងាយក្នុងការអនុវត្ត និងប្រើប្រាស់។

១១. យើងជឿជាក់ថាការបញ្ចេញព័ត៌មានអំពីការចំណាយ គឺគួរតែពាក់ព័ន្ធទាំងអស់នូវរាល់ដំណើរការក្រុមហ៊ុនឯកជនក្នុងវិស័យឧស្សាហកម្មនិស្សារណកម្មនៅក្នុងប្រទេសមួយ។

១២. ការរកដំណោះស្រាយ យើងត្រូវតែជឿជាក់ថា រាល់ស្ថាប័នដែលពាក់ព័ន្ធទាំងអស់សុទ្ធតែមានសារៈសំខាន់ និងពាក់ព័ន្ធក្នុងការជួយដោះស្រាយ រួមបញ្ចូលទាំងរដ្ឋាភិបាល និងភ្នាក់ងាររបស់ខ្លួន ក្រុមហ៊ុនឧស្សាហកម្មនិស្សារណកម្ម ក្រុមហ៊ុនផ្ដល់សេវាកម្ម អង្គការពហុភាគី ស្ថាប័នហិរញ្ញវត្ថុ អ្នកវិនិយោគទុន និងអង្គការក្រៅរដ្ឋាភិបាល។

*ប្រភពពី http://www.eiti.com*

# ព័ត៌មានសង្ខេប

## ៤០%នៃផ្ទៃដីខេត្តរតនគីរីបានធ្វើកិច្ចសន្យា ជួលឱ្យធ្វើការរុករករ៉ែ

ស្រុកអូយ៉ាដាវ ខេត្តរតនគីរី--ជាង៤០%នៃផ្ទៃដីខេត្តរតនគីរី ឬ ប្រហែល ៤,៤០០ គីឡូម៉ែត្រការ៉េ ត្រូវបានផ្តល់អាជ្ញាប័ណ្ណឱ្យទៅក្រុមហ៊ុនអាជីវកម្មរ៉ែចំនួន ១០ដើម្បីធ្វើការរុករករ៉ែក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ បើតាមទិន្នន័យផ្តល់ដោយអាជ្ញាធរខេត្តរតនគីរី។

បើទោះបីជាសកម្មភាពក្រុមហ៊ុនមានការកំណត់ក្នុងការធ្វើការរុករករ៉ែ ក៏មានសហគមន៍មួយចំនួននៅក្នុងខេត្តបានត្អូញត្អែរថា ប្រតិបត្តិការរបស់ក្រុមហ៊ុនទាំងនោះ បានរំខាន ឬ បំផ្លិចបំផ្លាញដីភូមិ និងព្រៃឈើរបស់ពួកគេ។ ក្រុមការងារសិទ្ធិមនុស្ស និងអង្គការមិន-មែនរដ្ឋាភិបាល និយាយថា ក្រុមហ៊ុន និងរដ្ឋាភិបាលត្រូវការធ្វើការពិភាក្សាឱ្យបានប្រសើរឡើងជាមួយសហគមន៍ក្នុងស្រុក មុននឹងចាប់ផ្តើមធ្វើការរុករក ឬដំណើរការអ្វីមួយ។

លោកម៉មសម្បត្តិប្រធានគណៈកម្មការអចិន្ត្រៃយ៍នៃបណ្តាញផលប៉ះពាល់សង្គម និងបរិស្ថានពីឧស្សាហ-កម្មនិស្សារណកម្ម បានមានប្រសាសន៍ថា បញ្ហាដែលធំជាងគេជុំវិញការប្រតិបត្តិរុករករ៉ែនៅខេត្តរតនគីរី គឺមានភាពខ្វះខាតលើការបើកទូលាយនូវព័ត៌មានពីសំណាក់ក្រុមហ៊ុនអាជីវកម្មរ៉ែ និងរដ្ឋាភិបាល ទៅដល់សហគមន៍មូលដ្ឋាន។

*(ចំណាំ: លោក ម៉ម សម្បត្តិ ក៏ជា ប្រធានក្រុមប្រឹក្សាភិបាលនៃសម្ព័ន្ធ-ភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន ។)*

*ប្រភព: ខេមបូឌាដេលី*

## ប្រទេសហ្គាណាធ្វើការបោះពុម្ពពីចំណូលប្រេង

រដ្ឋាភិបាលប្រទេសហ្គាណា បានយល់ព្រមធ្វើការផ្សព្វផ្សាយជាសាធារណៈ នូវចំណូលពីប្រេង និងឧស្ម័ននៅក្នុងប្រទេស បន្ទាប់ពីមានការយល់ព្រមពីគណៈរដ្ឋមន្ត្រីលើឯកសារដើម្បីពន្លឿនការបញ្ចូលប្រទេសហ្គាណាអោយចូលជាសមាជិក គំនិតផ្តួចផ្តើមដើម្បីតម្លាភាពឧស្សាហកម្មនិស្សារណកម្ម (អ៊ីអាយធីអាយ) លើការត្រួតពិនិត្យសាធារណៈនូវផលិតកម្ម និងការលក់ប្រេងឆៅទៅសាធារណជន ។

អ៊ីអាយធីអាយ គឺជាសម្ព័ន្ធភាពមួយរបស់រដ្ឋាភិ-បាល ក្រុមសង្គមស៊ីវិល អ្នកវិនិយោគ និងអង្គការអន្តរ-ជាតិ ដែលធ្វើការលើកកំពស់តម្លាភាព និងគណនេយ្យ-ភាពលើការរុករកឬ ឧស្សាហកម្មរ៉ែ ដូចជា មាស ពេជ្រ ប្រេង និង ឧស្ម័ន។

លោក Edward Bawa អ្នកនាំពាក្យរបស់រដ្ឋ-មន្ត្រីក្រសួងថាមពល មានប្រសាសន៍ថា រដ្ឋបានបង្កើតលេខាធិការដ្ឋាន ដែលត្រូវបានស្គាល់ថាវាជា ហ្គាណាអ៊ីអាយធីអាយ (GHEITI) នៅក្នុងក្រសួងផែនការហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ដើម្បីធ្វើការពិនិត្យចុងក្រោយលើឯកសារសំរាប់ប្រទេសហ្គាណា ដើម្បីទទួលបានសុពលភាពក្នុងការក្លាយជាសមាជិកភាព អ៊ីអាយ-ធីអាយ លើវិស័យប្រេង និងឧស្ម័ន។

ដើម្បីពន្លឿនដំណើរការនេះ លោកបានបន្ថែមថា រដ្ឋាភិបាលក៏បានបង្កើតគណៈកម្មាធិការ ដែលមានសមាជិកចំនួន ២០រូប ពីបណ្តាអ្នកពាក់ព័ន្ធទាំងឡាយនៅក្នុងវិស័យឧស្សាហកម្មនេះ ដើម្បីធានាចំពោះការពង្រីកគោលការណ៍របស់ អ៊ីអាយធីអាយ ទៅលើវិស័យប្រេង និងឧស្ម័ន ដោយសង្កត់ធ្ងន់ទៅលើថាផែនការរដ្ឋាភិបាលស្របទៅតាមបទដ្ឋានរបស់ អ៊ីអាយ-ធីអាយ ក្នុងវិស័យប្រេង និងឧស្ម័ន គឺជាសុច្ចនាករ ដែលធានាថា ចំណូលដែលមកពីឧស្សាហកម្មនេះ នឹងត្រូវបានប្រើប្រាស់ប្រកបដោយសុភវិនិច្ឆ័យ សំរាប់ផលប្រយោ-ជន៍ដល់ប្រជាពលរដ្ឋ។

លោកBawa បានមានប្រសាសន៍ថារបាយការណ៍ និងគណនេយ្យដែលមានក៏រិតស្តង់ដាខ្ពស់ និងស្របតាមច្បាប់អ៊ីអាយធីអាយ គឺមានភាពទាក់ទាញដល់អ្នកវិនិ-យោគ និងធានាឱ្យមានការបើកចំហក្នុងកិច្ចការពាណិជ្ជកម្ម។

លោក Bawa បានបន្ថែមថា "ជាមួយផលិតកម្មប្រេងឆៅប្រទេសហ្គាណា មានឱកាសអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមសម្រាប់ពលរដ្ឋ ដូច្នេះការបង្កើតតម្លាភាព និងគណនេយ្យភាព មានសារៈសំខាន់ ប្រសិនបើចំណូលទាំងនេះ យកទៅធ្វើការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តភាព។

*ប្រភពពី The Ghanian Times*

## ប្រទេសទីម័រឡេស្តេចូលរួម អ៊ីអាយធីអាយ

ប្រទេសទីម័រឡេស្តេ នៅថ្ងៃទី ០១ ខែ មិថុនា នេះ បានចូលរួមជាមួយអាហ្សែបៃហ្សង់ និងលីបេរីយ៉ា ជាប្រទេសទី ៣ ដែលបានបំពេញល័ក្ខខ័ណ្ឌពេញលេញរបស់អ៊ីអាយធីអាយ ។

ការផ្តួចផ្តើមរបស់អ៊ីអាយធីអាយ បង្កើតនូវបទដ្ឋានសកលមួយ សំរាប់តម្លាភាពលើវិស័យប្រេងឧស្ម័ន និងរ៉ែ ដែលតម្រូវឱ្យក្រុមហ៊ុនបង្ហាញ ការចំណាយទៅលើពន្ធ និងសួយសារអាករទៅឱ្យរដ្ឋាភិបាល។

ដូចគ្នានេះដែរ រដ្ឋត្រូវតែផ្សព្វផ្សាយនូវប្រាក់ដែលបានទទួលពីការបង់ថ្លៃរបស់ក្រុមហ៊ុនទាំងនោះ។

សុពលភាពមានពាក់ព័ន្ធនឹងការវាយតំលៃពីជនទីបី ពីខាងក្រៅ ពីដំណើរការរបស់ប្រទេសមួយក្នុងការបើកសៀវភៅរបស់ពួកគេ និងត្រូវបញ្ចប់ក្នុងគម្រោងពីរឆ្នាំម្តង។

*ប្រភពពី: Upstreamonline.com*

*សង្ខេបដោយ: Frank Yetter បុគ្គលិក CRRT*

តមកពីទំព័រទី ៦

## ធ្វើការដើម្បីធានា...

មាស មុំ ជាអ្នកដែលបានឃើញ និងឮ ពីការជីកអណ្តូងក្រុមហ៊ុនរ៉ែមាសរបស់ចិន នៅចំពីខាងមុខជណ្តើរផ្ទះរបស់គាត់ នៅក្នុងភូមិព្រៃមាស ក្នុងខេត្តមណ្ឌលគិរី ដែលកន្លែងនោះល្បីថាជា "ព្រៃសំបូរមាស" បានមានប្រសាសន៍ថា "យើងជាប្រជាពលរដ្ឋ-សាមញ្ញ មិនបានស្គាល់សូម្បីតែឈ្មោះក្រុមហ៊ុន។ ហើយពួកគេក៏នឹងមិនប្រាប់យើងដែរ"។

ខណៈពេលដែលមានការសប្បាយរីករាយពីព័ត៌មានពីការរកឃើញធនធាន តែបែរជាពលរដ្ឋកម្ពុជាមានការយល់ដឹងតិចតួចទៅលើគ្រោះថ្នាក់ ឬផលប៉ះពាល់ដល់សង្គម និងបរិស្ថាន ដែលកើតមកពីការជីកយករ៉ែ។ ប្រជាពលរដ្ឋដែលរស់នៅក្នុង ខេត្ត-មណ្ឌលគិរី យល់ដឹងតិចតួចខ្លាំងណាស់ពីអ្វីៗដែលជា "បណ្តាសារធនធាន" នៅពេលដែលប្រទេសសំបូរដោយធនធានធម្មជាតិ តែបែរជាកាន់តែក្រទៅៗដោយសារតែការជីកយករ៉ែរបស់ពួកគេ។

អង្គការអន្តរជាតិមួយចំនួន ដូចជាអុកស្វាម បានបន្តកិច្ចការរបស់ខ្លួនដើម្បីបង្កើតចំណងទាក់ទងរវាងក្រុមហ៊ុន និងសាធារណជន ដើម្បីពិភាក្សាពីវិធីបង្កើតឱ្យមាននូវច្បាប់ និងឯកសារគតិយុត្តិឱ្យបានគ្រប់គ្រាន់ ដើម្បីគ្រប់គ្រងទៅលើវិស័យឧស្សា-ហកម្មនិស្សារណកម្ម ដែលកំពុងតែចាប់កំណើត និងគ្រប់គ្រងទៅលើក្តីរំពឹងទុកមិនប្រាកដប្រជាទៅលើអ្វីដែលវិស័យនេះអាចផ្តល់ឱ្យ។

លោក Brian Lund នាយកប្រចាំតំបន់អាស៊ីបូព៌ានៃអង្គការអុកស្វាមអាមេរិក បានមានប្រសា-សន៍ថា វាអាចនឹងកើតឡើងទៅបានតាមរយៈដំណើរការតម្លាភាព និងការទទួលខុសត្រូវ ដែលប្រទេសកម្ពុជា អាចទាញយកសក្តានុពលពីការដកហូតយកធនធាន និងប្រើប្រាស់ប្រាក់ចំណេញទាំងនោះ ដើម្បីជួយប្រជាពលរដ្ឋក្រីក្រតាមរយៈការអភិវឌ្ឍ។/



*រូបថត: sila_pic1 (http://pennystocknewsletter.info/stock-picks/sila-tgmp-stock-to-watch-by-crwewallstreet-com-for-august-31st-2010-stock-alerts)*

តមកពីព្រឹត្តិបត្តិលេខទី៤

# តម្លាភាពមានការកើនឡើង ប៉ុន្តែវាស្ថិតលើកំណាត់ផ្លូវឆ្ងាយ

*ដោយ Steve Finch, ភ្នំពេញប៉ុស្តិ៍*

**តើមានតម្លាភាពពេញលេញដែរឬទេ?**

ជាការពិតរដ្ឋាភិបាល ហាក់ដូចជាមិនទាន់បានសម្រេចចិត្តនៅឡើយទេថា តើខ្លួនត្រៀមខ្លួនបង្ហាញព័ត៌មានក្នុងកម្រិតប៉ុនណាទេ ទាក់ទងនឹងទឹកប្រាក់ដែលទទួលបានពីក្រុមហ៊ុនរុករកប្រេងឧស្ម័ននិងរ៉ែ។

ព័ត៌មាន ដែលមានចំណងជើងថា "ការលាតត្រដាងនៃគម្រោងផ្តួចផ្តើមតម្លាភាពក្នុងឧស្សាហកម្មរុករករ៉ែ (EITI) " ដែលលោក ហង់ ជួនណារ៉ុន បានលើកយកមកបង្ហាញ បានឆ្លុះបញ្ចាំងឱ្យឃើញពីកិច្ចប្រឹងប្រែងដំបូងរបស់រដ្ឋាភិបាលក្នុងការអនុលោមទៅតាម EITI ដែលសម្ព័ន្ធសកលនៃបណ្តារដ្ឋាភិបាល ក្រុមហ៊ុនឯកជន និងក្រុមសង្គមស៊ីវិលព្យាយាមលុបបំបាត់មិនឱ្យមានការបង់ប្រាក់ដោយសម្ងាត់គ្រប់ប្រភេទ ហើយមានការចុះផ្សាយថា ការបង់ប្រាក់ប្រភេទនេះ បានញាំញីវិស័យធនធានរ៉ែនៅកម្ពុជា។

លោក Sam Bartlett នាយក EITI ប្រចាំតំបន់អាស៊ី បានឱ្យដឹងថា រដ្ឋាភិបាលកម្ពុជា បានជួបជាមួយតំណាង EITI កាលពីឆ្នាំមុន ហើយក៏កំពុងពិចារណាពីលក្ខខណ្ឌក្នុងការអនុវត្តគោលនយោបាយមួយចំនួន ដូចជា "ការបង្ហាញព័ត៌មានទ្វេដង" ដែលនឹងតម្រូវឱ្យក្រុមហ៊ុនរដ្ឋ និងឯកជនផ្តល់ព័ត៌មានហិរញ្ញវត្ថុសម្រាប់ការពិនិត្យតាមដានដោយឯករាជ្យ។

លោកបានឱ្យដឹង កាលពីថ្ងៃពុធថា "ភាគីពាក់ព័ន្ធនៅកម្ពុជាមានទស្សនៈផ្សេងៗថា តើ EITI ជាគំរូត្រឹមត្រូវដែរឬទេ ហើយក៏មានការពិភាក្សាជាបន្តបន្ទាប់អំពីថ្លៃចំណាយ និងអត្ថប្រយោជន៍របស់ EITI សម្រាប់កម្ពុជាផងដែរ"។

ទន្ទឹមនឹងនេះដែរ ភស្តុតាងអំពីការចំណាយប្រាក់រាប់លានដុល្លា ដោយក្រុមហ៊ុនមួយចំនួន ដូចជា BHP ក្រុមហ៊ុនរុករកថាមពលតូតាល់របស់បារាំងនិងក្រុមហ៊ុនរុករករ៉ែឧស្ម័ននិងប្រេងផ្សេងៗទៀត ដែលកំពុងធ្វើអាជីវកម្មនៅកម្ពុជា បានឱ្យសាធារណៈមានចម្ងល់ច្រើនជាងការផ្តល់ចម្លើយ។

កាលពីថ្ងៃទី ៧ ខែ ឧសភា លោក សុន ឆ័យ សមាជិកសភាមកពីគណបក្សសម រង្ស៊ី បានផ្ញើសំណួរជាច្រើនទៅកាន់រដ្ឋាភិបាល ដែលទទួលដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន ។សំណួរទាំងអស់នោះ បានតម្រូវឱ្យឧបនាយករដ្ឋមន្ត្រី សុខ អាន ឆ្លើយលម្អិតអំពីទឹកប្រាក់ ដែលក្រុមហ៊ុន BHP និងតូតាល់ បានផ្តល់ដល់រដ្ឋាភិបាល ដែលនាំឱ្យមានការចោទប្រកាន់កើតឡើង ។ថ្ងៃនេះ(១៤ឧសភា) នឹងដល់ថ្ងៃកំណត់ដែលត្រូវផ្តល់ចម្លើយទាក់ទងនឹងសំណួរទាំងអស់នោះ ហើយបើតាមពិធីសាររបស់សភាកម្ពុជា។

កាលពីថ្ងៃពុធ លោក សុន ឆ័យ បានលើកឡើងថា "បញ្ហាការចំណាយរបស់ក្រុមហ៊ុន បានក្លាយជាបញ្ហាពិត" ដោយលោកបានចោទប្រកាន់រដ្ឋាភិបាលពីការក្លែងបន្លំឯកសារហិរញ្ញវត្ថុ ដើម្បីបំភាន់ភ្នែកអំពើពុករលួយពីអតីតកាល ជ្រកឈ្មោះតម្លាភាព "ដើម្បី គ្រាន់តែការដោះស្រាយសម្ពាធនេះតែប៉ុណ្ណោះ"។

លោកបានបន្ថែមថា លោកបានឃើញភស្តុតាងដែលក្រុមហ៊ុនបរទេសមួយ បានផ្តល់ប្រាក់មិនផ្លូវការ ១ លានដុល្លា កាលពី ឆ្នាំ ១៩៩៩ ដល់មន្ត្រីរដ្ឋាភិបាល បន្ទាប់ពីចុះកិច្ចព្រមព្រៀង ស្តីពី ការធ្វើសម្បទានរុករករ៉ែ។

ប្រសិនបើលោក សុខ អាន ឆ្លើយលម្អិតទៅនឹងការចោទសួររបស់គណបក្សសម រង្ស៊ី នេះជាលើកដំបូងហើយដែលរដ្ឋាភិបាល នឹងលាតត្រដាងព័ត៌មានអំពីប្រាក់ទទួលបានពីឧស្សាហកម្មរុករករ៉ែ ដើម្បីជាការឆ្លើយតបទៅនឹងសំណួររបស់សភា។

នៅសប្តាហ៍នេះ ទាំងលោក សុខ អាន និង លោក មែន ឌិន ប្រធានផ្នែករុករកប្រេង និងផលិតកម្មនៃអាជ្ញាធរប្រេងកាតជាតិកម្ពុជា មិនបានឆ្លើយតបទៅនឹងសំណើជាលាយលក្ខណ៍អក្សរ ដើម្បីឱ្យមានការផ្តល់ព័ត៌មានបន្ថែមទាក់ទងនឹងបញ្ហានោះឡើយ។

## ការរក្សាការសម្ងាត់

ភាគច្រើននៃកង្វះភាពបើកចំហ ហាក់ដូចជាមានទំនាក់ទំនងទៅនឹងកិច្ចសន្យា ដែលបានចរចាគ្នារួចហើយ នៅតែជាចំនុចមួយសំខាន់នៃវិស័យរុករករ៉ែនៅកម្ពុជា។ ប្រសិនបើរដ្ឋាភិបាល បានបង្កើនតម្លាភាពនាពេលថ្មីៗនេះ ទោះបីចាប់ផ្តើមពីកម្រិតទាបក៏ដោយ នោះកិច្ចសន្យាជាមួយឧស្សាហកម្មរុករករ៉ែ នឹងកាន់តែមានភាពតឹងរ៉ឹង ទាក់ទងនឹងការអនុញ្ញាតឱ្យបើកចំហព័ត៌មានឱ្យសាធារណជនដឹង។

ឧទាហរណ៍មួយទាក់ទងនឹងកិច្ចសន្យាស្តីពីការរុករកប្រេងនៅកម្ពុជា ចាប់តាំងពីឆ្នាំ១៩៩១ ដែលបានបោះពុម្ពផ្សាយកាលពីឆ្នាំមុន ដោយ EITI បានបញ្ជាក់ថា ទិន្នន័យទាក់ទងនឹងកិច្ចព្រមព្រៀងអនាមិកនេះ "ត្រូវរក្សាការសម្ងាត់ ក្នុងអំឡុងពេលអនុវត្តកិច្ចព្រមព្រៀងនោះ។ បើយោងតាម EITI ឧទាហរណ៍ក្រោយៗមកទៀត នៅឆ្នាំ២០០២ ឆ្នាំ២០០៨ និងនៅឆ្នាំមុន និងទាមទារមិនឱ្យបង្ហាញជាសាធារណៈឡើយ រហូតដល់២ឆ្នាំក្រោយពីកិច្ចព្រមព្រៀងនោះបានបញ្ចប់ទៅ។

នៅពេលដែលភ្នំពេញប៉ុស្តិ៍សាកសួរទៅក្រុមហ៊ុន Chevron ដែលទំនងជាក្រុមហ៊ុនដំបូងគេនឹងផលិតប្រេងនៅកម្ពុជា ឱ្យបង្ហាញពីប្រាក់បន្ថែមនិងមូលនិធិសង្គម ដែលក្រុមហ៊ុនរបស់លោក ផ្តល់ដល់រដ្ឋាភិបាល។ លោក Gareth Johnstone អ្នកនាំពាក្យប្រចាំតំបន់របស់ក្រុមហ៊ុននេះ បានឆ្លើយមកវិញ កាលពីថ្ងៃព្រហស្បតិ៍ថា "កិច្ចព្រមព្រៀងរបស់យើងជាមួយរាជរដ្ឋាភិបាលកម្ពុជា មិនអនុញ្ញាតឱ្យបង្ហើបជាសាធារណៈឡើយ អំពីការចំណាយប្រាក់ ឬ ព័ត៌មានសម្ងាត់ផ្សេងទៀត ដែលមានលក្ខណៈជាអាជីវកម្ម"។

ដូចដែលលោក Bartlett បម្រើការនៅ EITI បានលើកឡើងដែរ រដ្ឋាភិបាលត្រូវទទួលខុសត្រូវធំចំពោះការធ្វើឱ្យមានតម្លាភាពពេញលេញ។ ទីបំផុត EITI គឺជាអ្នកផ្តួចផ្តើមគំនិតសម្រាប់ប្រទេសមួយទៅវិញ។

សម្រាប់ករណីនៅកម្ពុជា ការបង្ហាញព័ត៌មានកាលពីថ្មីៗនេះនៅតែមិនទៀងទាត់ ហើយកើតឡើងដោយគ្មានព្រាងទុកកាន់តែធ្វើឱ្យមានការភាន់ច្រលំ។

កាលពីខែមុនលោក ហ៊ុន សែន បានបញ្ជាក់ជាសាធារណៈថា ក្រុមហ៊ុន តូតាល់ បានចំណាយប្រាក់បន្ថែមលើការចុះហត្ថលេខា ២០លានដុល្លា និងមូលនិធិសង្គម ៨លានដុល្លា សម្រាប់កិច្ចព្រមព្រៀងទទួលបានតំបន់សម្បទានរុករករ៉ែ ក្នុងសមុទ្រនៅប្លុកទី III ជាប្លុកមានជម្លោះជាមួយនឹងថៃ កាលពីខែតុលា ប៉ុន្តែការនេះនៅតែមិនមានភាពច្បាស់លាស់ដដែល ថាតើលុយទាំងនោះបានយកទៅចំណាយលើអ្វីខ្លះ ហើយចំណាយនៅពេលណា។

អ្នកស្រី Phenelope Semavoine អ្នកនាំពាក្យរបស់ក្រុមហ៊ុនតូតាល់ បានឱ្យដឹងតាមអ៊ីម៉ែលកាលពីថ្ងៃអង្គារថា ការចំណាយ ទាំងនេះ ទាក់ទងនឹងព័ត៌មាន EITI ដែលបង្ហាញដោយលោក ហង់ ជួនណារ៉ុន កាលពីខែមករា ទាក់ទងនឹងមូលនិធិ សង្គម គឺមានតែ ៦លានដុល្លា ប៉ុណ្ណោះ មិនមែន ៨លានដុល្លាឡើយ។

លោកស្រីបានលើកឡើងថា "ការចំណាយទៅលើមូលនិធិសង្គមជាបន្តបន្ទាប់ ដែលមានចំនួន ២លានដុល្លាបន្ថែមទៀត នឹងធ្វើឡើងនៅពេលក្រោយ"។

អ្នកស្រីបានបន្ថែមថា ក្រុមហ៊ុនតូតាល់ និងរដ្ឋាភិបាល នឹងគ្រប់គ្រងមូលនិធិសង្គមនេះរួមគ្នា ដោយមូលនិធិនោះនឹងយកទៅចំណាយលើការអប់រំ និងសេវាសុខភាពនៅកម្ពុជា។

អ្នកស្រីបដិសេធតួលេខខុសគ្នានេះ ដោយសង្កត់ធ្ងន់ថា "ប្រទេសនីមួយៗមានអធិបតេយ្យភាពរបស់ខ្លួន។ ប្រសិនបើប្រទេសមួយបើកសៀវភៅ

តទៅទំព័របន្ទាប់

តមកពីទំព័រទី ៦

## វគ្គបណ្តុះបណ្តាល ស្តីពី អភិបាលកិច្ចប្រេង...

ជម្រើសនូវការទាញយកប្រយោជន៍នៃធនធានប្រេងរបស់ប្រទេសមួយ ដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋរបស់ខ្លួន។ សំរាប់កម្ពុជា ទោះបីជាចំណេះដឹងលើវិស័យនេះនៅមានកំរិត តែរាជរដ្ឋាភិបាលកម្ពុជា បានព្យាយាមប្រឹងប្រែងក្នុងការតាក់តែងច្បាប់ពាក់ព័ន្ធ បង្កើតក្រុមការងារបច្ចេកទេសសិក្សាលើវិស័យនេះ និងការអភិវឌ្ឍធនធានមនុស្សតាមរយៈការបញ្ជូនបុគ្គលិកជំនាញទៅទស្សនកិច្ចនៅបរទេស និងទទួលវគ្គបណ្តុះបណ្តាលផ្សេងៗ។

លោក ឆាយ សារ៉ាត អ្នកបណ្តុះបណ្តាលវេទិកា និងជាអ្នកសម្របសម្រួលសម្ព័ន្ធភាព ស៊ីអារអាធី បានមានប្រសាសន៍ថា "ការដែលបង្កើតឱ្យមានវគ្គបណ្តុះបណ្តាលយុវជនលើការគ្រប់គ្រងធនធានលើវិស័យប្រេង វានឹងធ្វើឱ្យពួកគាត់យល់ដឹងពីចំណេះដឹងមូលដ្ឋាន និងទស្សនទាននៃវិស័យប្រេងដើម្បីឱ្យពួកគេអាចធ្វើការពិភាក្សាជាមួយមិត្តភ័ក្រ្ត និងធ្វើឱ្យការចូលរួមរបស់ពួកគាត់នៅក្នុងវេទិកាសាធារណៈមានប្រសិទ្ធិភាព នៅពេលដែលពួកគាត់មានឱកាសសួរទៅអ្នកជំនាញ និងមន្ត្រីរដ្ឋាភិបាល"។

ដើម្បីឱ្យការគ្រប់គ្រងវិស័យនេះ ប្រកបដោយតម្លាភាពនិងប្រសិទ្ធិភាព និងផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប រាល់ព័ត៌មានពីការវិនិយោគលើវិស័យនេះ គួរត្រូវបានផ្សព្វផ្សាយឱ្យទូលំទូលាយដល់សាធារណជន និងផ្តល់ឱកាសដល់ពួកគាត់ក្នុងការចូលរួមធ្វើសេចក្តីសំរេចទៅលើការប្រើប្រាស់ចំណូលដើម្បីបំពេញនូវតំរូវការពិតប្រាកដរបស់ពួកគាត់។

កញ្ញា ភ័ក្រា បាននិយាយថា "ខ្ញុំគិតថាវគ្គនេះពិតជាមានអត្ថប្រយោជន៍ចំពោះនាងខ្ញុំ ក្នុងនាមជានិស្សិត និងជាពិសេសក្នុងនាមជាពលរដ្ឋខ្មែរមួយរូប ពីព្រោះវាជាប្រធានបទមួយថ្មីស្រឡាងដែលកើតឡើងនៅកម្ពុជា។ ហើយខ្ញុំក៏សង្ឃឹមថាប្រជាពលរដ្ឋទាំងឡាយ ពិសេសយុវជន ក៏គួរតែដឹងពីព័ត៌មានទាំងអស់នេះព្រោះវាជាអនាគតរបស់ជាតិយើង"។/

តមកពីទំព័រទី ៤

## តម្លាភាពមានការកើនឡើង...

បញ្ជីរបស់ខ្លួន គឺមានបង្ហាញពីចំនួនណាមួយដែលក្រុមហ៊ុនឯកជនអាចចំណាយ"។

ទាំងក្រុមហ៊ុនChevron និងក្រុមហ៊ុន តូតាល់ សុទ្ធតែត្រូវបានចុះបញ្ជីថាជាក្រុមហ៊ុនដែលគាំទ្រដល់ EITI ។

ក្រុមហ៊ុន Southern Gold របស់អូស្រ្តាលី ដែលរុករករ៉ែនៅលើដីសម្បទានក្នុងព្រះរាជាណាចក្រកម្ពុជា មិនបាន "ចំណាយប្រាក់ ឬថ្លៃចំណាយប្រភេទនោះឡើយ"។ នេះបើយោងតាម លោក Grant Thomas តំណាងរបស់ក្រុមហ៊ុននេះនៅកម្ពុជា ដែលបានបញ្ជាក់ឱ្យដឹងកាលពីថ្ងៃពុធតាមរយៈអ៊ីម៉ែល។

កាលពីថ្ងៃព្រហស្បតិ៍ ម្សិលមិញ ក្រុមហ៊ុន OZ Minerals ដែលរុករករ៉ែនៅកម្ពុជា មិនបានឆ្លើយតបទៅនឹងសំណួរ ទាក់ទងនឹងការចំណាយឡើយ នៅពេលដែលកាសែតបានចោទសួរអំពីសំណួរនេះ ទោះបីជាលោក ម៉ម សម្បត្តិ ប្រធាន CRRT បានឱ្យដឹងថា តំណាងរបស់ក្រុមហ៊ុននេះបានប្រាប់លោក កាលពីលើកមុនថា ក្រុមហ៊ុននេះ មិនបានចំណាយប្រាក់ដល់រដ្ឋាភិបាល ដើម្បីទទួលបានការចុះកិច្ចព្រមព្រៀងទទួលបានដីសម្បទានឡើយ។

ដូច្នេះ វានៅតែមិនច្បាស់លាស់ ថាតើក្រុមហ៊ុនរុករករ៉ែមួយណា ដែលបានផ្តល់ប្រាក់ ១,៤៥លានដុល្លា ដល់រដ្ឋាភិបាលកាលពីឆ្នាំមុន ដើម្បីរុករករ៉ែនៅកម្ពុជា។ នេះបើយោងតាមកំណត់ត្រា TOFE របស់រដ្ឋាភិបាល។ នៅតែមានភាពច្របូកច្របល់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីឱ្យមានតម្លាភាពលើច្បាប់ដែលទន្ទឹងរង់ចាំ ការអនុម័ត ដើម្បីគ្រប់គ្រងវិស័យរុករកប្រេងនិងឧស្ម័ននិងការចូលរួមរបស់ភាគីមកពីសង្គមស៊ីវិល ក្នុងកិច្ចពិភាក្សាជាមួយរដ្ឋាភិបាល ស្តីពី ប្រាក់ចំណូលទទួលបានពីវិស័យឧស្សាហកម្មរុករកប្រេង។

**កង្វះការចូលរួមពីសង្គមស៊ីវិល**

លោក ម៉ម សម្បត្តិ បានឱ្យដឹងថា ទោះបីជា CRRT និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗទៀត ត្រូវបានផ្តល់ឱ្យអង្កេតលើក្រុមការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ ដែលបានបង្កើតឡើងកាលពីដើមឆ្នាំមុន ហើយគ្រប់គ្រងដោយក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាជ្ញាធរជាតិប្រេងកាតកម្ពុជា និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ព្រមទាំងក្រសួងបរិស្ថានក៏ដោយ អង្គការទាំងនោះ ត្រូវបានបដិសេធមិនឱ្យទទួលបានឱកាសចូលរួមក្នុងនាមជាដៃគូពិភាក្សាឡើយ។

ស្រដៀងគ្នានេះដែរ អង្គការសង្គមស៊ីវិលផ្សេងទៀត បានត្អូញត្អែរថា ពួកគេមិនត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការធ្វើសេចក្តីព្រាងច្បាប់សំខាន់ៗពីរ សម្រាប់យកទៅគ្រប់គ្រងឧស្សាហកម្មថាមពល នៅពេលដែលចាប់ផ្តើមមានផលិតកម្មអាចឆាប់បំផុតនៅឆ្នាំ ២០១២។ ច្បាប់ទាំងពីរនោះគឺច្បាប់ប្រេងកាត និងច្បាប់ស្តីពីការយកពន្ធប្រាក់ចំណូលពីប្រេង ឧស្ម័ន និងរ៉ែ។

កាលពីថ្ងៃព្រហស្បតិ៍ លោក Johnstone បានអះអាងថា ក្រុមហ៊ុន Chevron នៅតែបន្តជួយរដ្ឋាភិបាលនៅក្នុងដំណើរការធ្វើសេចក្តីព្រាងច្បាប់នេះ ប៉ុន្តែមិនមានភាគីណាមួយ បានចេញផ្សាយព័ត៌មានលម្អិតទាក់ទងនឹងអ្វីដែលបានដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់នោះឡើយ។ បច្ចុប្បន្នសេចក្តីព្រាងច្បាប់នេះស្ថិតក្រោមការវាយតម្លៃរបស់ទីស្តីការគណៈរដ្ឋមន្ត្រី បើយោងតាមលោក ផៃ ស៊ីផាន អ្នកនាំពាក្យរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ក្រៅពីនេះអង្គការសហប្រជាជាតិ បានចោទសួរពីកម្រិតនៃអំណាចដែលផ្តល់ឱ្យអាជ្ញាធរជាតិប្រេងកាតកម្ពុជា ដែលជាស្ថាប័នមួយបង្កើតឡើងដោយរដ្ឋាភិបាល កាលពីឆ្នាំ ១៩៩៨ ដើម្បីគ្រប់គ្រងឧស្សាហកម្មរុករកប្រេង។

នៅក្នុងឯកសារពិភាក្សាឆ្នាំ ២០០៦ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) បានព្រមានថា អាជ្ញាធរប្រេងកាតជាតិកម្ពុជា ដែលស្ថិតក្រោមការមើលខុសត្រូវដោយផ្ទាល់របស់ លោក សុខ អាន ទទួលបានអំណាចក្នុងការចេញអាជ្ញាប័ណ្ណដល់ឈ្មួញធ្វើអាជីវកម្មប្រេងឆៅ និងក្រុមហ៊ុននាំចូលប្រេងចម្រាញ់រួច។

ឯកសារនោះបានលើកឡើងថា "ប្រសិនបើក្រុមហ៊ុនកម្ពុជាមួយដែលផ្តល់សេវាហិរញ្ញវត្ថុ ឬជាក្រុមហ៊ុនអាជីវកម្មកម្ពុជា ឬជាក្រុមហ៊ុនប្រេងអន្តរជាតិ ដែលមានការិយាល័យនៅកម្ពុជាមានបំណងចង់ទិញ ឬ លក់ប្រេងនៅនៅលើទីផ្សារសិង្ហបុរី គឺវាមិនច្បាស់លាស់ទេ ថាហេតុអ្វីបានជាគេតម្រូវឱ្យសុំអាជ្ញាប័ណ្ណពីអាជ្ញាធរប្រេងកាតជាតិកម្ពុជា"។

លោក សុន ឆ័យ សមាជិកសភាមកពីគណបក្សសម រង្ស៊ី បានចោទប្រកាន់ថាប្រើប្រាស់អាជ្ញាប័ណ្ណ ដើម្បីជាយានទាក់ទាញប្រាក់ក្រៅផ្លូវការពីក្រុមហ៊ុនឯកជន ជាពិសេសវិស័យទូរស័ព្ទចល័ត។

លោក ម៉ម សម្បត្តិ បានលើកឡើងថា "ប្រសិនបើ រដ្ឋាភិបាលមានឆន្ទៈចង់លើកកម្ពស់តម្លាភាពនិងគណនេយ្យភាព ការចុះឈ្មោះចូលក្នុង EITI ជាជម្រើសដ៏ប្រសើរបំផុតសម្រាប់សង្គមកម្ពុជា"។

ចំពោះចំណុចនេះ EITI បានបញ្ជាក់ថា ខ្លួនស្វាគមន៍ជានិច្ចចំពោះឱកាសក្នុងការធ្វើការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល។ ប៉ុន្តែ ថាតើ រដ្ឋាភិបាលមានឆន្ទៈគាំទ្រ ឬ មិនគាំទ្រនេះ នឹងជាការធ្វើតេស្តសាកល្បងដ៏ល្អបំផុតសម្រាប់តម្លាភាពក្នុងវិស័យរុករកប្រេងរ៉ែនិងឧស្ម័ននៅកម្ពុជានាថ្ងៃអនាគត។/

*ប្រែសម្រួល ឈួ សុខចេង*

*អត្ថបទមានការសុំសិទ្ធិឱ្យបោះពុម្ពឡើងវិញពី ភ្នំពេញប៉ុស្តិ៍ (ថ្ងៃសុក្រ ទី១៤ ខែឧសភា ឆ្នាំ២០១០)*

## ធ្វើការដើម្បីធានាបានពរជ័យពីធនធាន

*ខណៈមានការសប្បាយរីករាយចំពោះការរកឃើញរ៉ែ ប្រេង និងឧស្ម័ន ពលរដ្ឋកម្ពុជាមានការប្រយ័ត្នប្រយែងចំពោះ ការគ្រប់គ្រងដែលអាចកើតមាន និងបញ្ហាតម្លាភាព។*

*ដោយ ស៊ាង សុលក្ខណ៍ បុគ្គលិក អុកស្វាមអាមេរិក*

ភ្នំពេញ-នៅក្នុងតំបន់ព្រៃភូមិភាគឥសាន្តនៃខេត្តមណ្ឌលគិរី សហគមន៍ជនជាតិមិនសូវមានការ-ទំនាក់ទំនងជាមួយប្រជាជនខ្មែរក្រៅពីភូមិរបស់ពួកគាត់ឡើយ។ នៅរដូវវស្សា ផ្លូវដែលនាំទៅកាន់សហគមន៍ទាំងនេះ គឺជាទូទៅមានភក់ជ្រាំ និងបត់បែនកាត់តាមទឹកភក់ ហើយមានតែអ្នកធ្វើដំណើរដែលស្ទាត់ជំនាញក្នុងការបើកបរម៉ូតូប៉ុណ្ណោះដែលអាចធ្វើដំណើរទៅបាន ឬ អាចជិះត្រង់កាត់តាមច្រក និងជ្រលងភ្នំដែលមានព្រៃក្រាស់ឃ្មឹកនេះ។



*រូបថត: អ្នកជីករ៉ែក្នុងស្រុកថតរូបនៅតំបន់អាជីវកម្មរ៉ែខេត្តមណ្ឌលគិរី*

តំបន់ជនបទដាច់ស្រយាលមួយដូចទាំងនេះ ឥឡូវកំពុងតែឃើញមានអ្នកមកមើលឥតដាច់ជាមួយនឹងការរកឃើញនូវ រ៉ែមាស រ៉ែបុកស៊ីត និងរ៉ែផ្សេងៗទៀតនៅក្នុងព្រៃនេះ។ ផ្លូវមានលក្ខណៈធំទូលាយសំរាប់ត្រាក់ទ័រ និងរថយន្តសណ្តោង ដែលឃើញមាននៅតាមកន្លែងនេះនោះ កំពុងត្រូវបានជីកកកាយ និងកៀរពង្រាបដីយ៉ាងស្អាត។ នៅរដូវប្រាំង អ្នកអាចឃើញមានឧបករណ៍ធំធ្ងន់ៗ ពីក្រុមហ៊ុនរ៉ែរកស៊ីជីកឈើ ដែលជាទូទៅបណ្តាក្រុមហ៊ុនមានម្ចាស់ជាជនជាតិចិន កូរ៉េ ឬវៀតណាម។

ទីនេះអាចនិយាយបានថា នេះជាពេលវេលានិងជាឱកាសដ៏ល្អ ប៉ុន្តែក៏ជាភាពប្រថុយប្រថានដែរ។ មានបណ្តាក្រុមហ៊ុនបរទេសជាច្រើន ធ្វើការវិនិ-យោគទៅលើការរុករករ៉ែនៅក្នុងព្រៃ ក៏ដូចជារុករកប្រេងនៅលើគោក និងនៅក្នុងទឹក។ វិនិយោគិនសំខាន់ៗរួមមាន ក្រុមហ៊ុនChevron, BHP, តូតាល់ និងវិនិយោគិនធុនតូច មានដូចជា ក្រុមហ៊ុនចិន ថៃ ម៉ាឡេស៊ី កូរ៉េខាងត្បូង និងវៀតណាម ដែលពិបាកនឹងស្គាល់ឈ្មោះ ហើយវាកាន់តែពិបាកជាងនេះទៅ-ទៀត គឺនៅក្នុងការប្រមូលព័ត៌មានពីកិច្ចសន្យា និងការបង់ចំណាយផ្សេងៗរបស់ក្រុមហ៊ុនពួកគេ។

**តទៅទំព័រទី ៣**

## វគ្គបណ្តុះបណ្តាល ស្តីពី អភិបាលកិច្ចក្នុងវិស័យប្រេង និងឧស្ម័ន

*ដោយ បុគ្គលិក វ៉ាយអាឌីភី*

ដោយមានការសហការរវាងអង្គការ កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP) និងសម្ព័ន្ធភាពកម្ពុជាតម្លាភាពចំណូលធនធាន(CRRT) យុវជនជាង ៣០រូប ដែលមកពីសកលវិទ្យាល័យផ្សេងៗនៅក្នុងទីក្រុងភ្នំពេញ ត្រូវបានផ្តល់ឱកាសចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលកាលពីថ្ងៃទី៧-៨ ខែកក្កដា ២០១០ ស្តីអំពី "អភិបាលកិច្ចក្នុងវិស័យប្រេង និងឧស្ម័ន"។

វគ្គបណ្តុះបណ្តាលនេះ មានគោលបំណង (១) ផ្តល់ឱ្យយុវជននូវទិដ្ឋភាពទូទៅអំពីអាប់ស្ទ្រីម (upstream) នៅក្នុងឧស្សាហកម្មប្រេង និងឧស្ម័ន ការអនុវត្តដ៏ប្រសើរ និងបទពិសោធន៍អភិបាលកិច្ចប្រេង និងឧស្ម័នមកពីបណ្តាប្រទេសផ្សេងៗ (២) លើកកម្ពស់សមត្ថភាពយុវជន និងសង្គមស៊ីវិលចូលរួមពិភាក្សាអំពី បញ្ហាពាក់ព័ន្ធក្នុងតម្លាភាពគ្រប់គ្រងការឃ្លាំមើលនូវការប្រើប្រាស់ចំណូលធន-ធាន និងបណ្តាសាធនធាន (៣) ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយក្នុងការគ្រប់គ្រងវិស័យប្រេង និង (៤) បង្កើតជាវេទិកាបើកចំហមួយ ដើម្បីការរៀនសូត្រ ពិភាក្សា និងចែករំលែកចំណេះដឹងរវាងគ្នា។

ទោះបីជាវគ្គបណ្តុះបណ្តាលនេះ វាហាក់បីដូចជាបច្ចេកទេសសំរាប់និស្សិត តែពួកគេមានការចាប់-អារម្មណ៍ជាខ្លាំង និងភ្ញាក់ផ្អើលចំពោះព័ត៌មានដែលពួកគេបានទទួលពីការវគ្គបណ្តុះបណ្តាល ហើយមានការចូលរួមយ៉ាងសកម្មក្នុងការជជែកពិភាក្សា និងដេញដោលពីចំណុចនីមួយៗ។

កញ្ញា ភ័ក្រ្តា និស្សិតឆ្នាំទី១ នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ បាននិយាយថា "ខ្ញុំរីករាយណាស់ដែលមានឱកាសចូលរួម នៅក្នុងវគ្គបណ្តុះបណ្តាលនេះ ព្រោះខ្ញុំបានរៀនសូត្រនូវចំណេះដឹងជាច្រើន ដូចជា អភិបាលកិច្ចក្នុងវិស័យឧស្សាហកម្មនិស្សារណកម្ម អាប់ទ្រីម ខ្សែចង្វាក់តំលៃក្នុងវិស័យប្រេង និងឧស្ម័ន និងអ្វីទៅជា អ៊ីអាយធីអាយ"។

ក្នុងរយៈពេល២ថ្ងៃពេញ និស្សិតបានទទួលចំណេះដឹងជាច្រើន ដូចជា អភិបាលកិច្ចឧស្សាហកម្មនិស្សារណកម្ម អ៊ីអាយធីអាយ ទិដ្ឋភាពអាប់ស្ទ្រីម ដំណាក់កាល និងតួនាទីក្នុងការអភិវឌ្ឍវិស័យប្រេងកាត ។ល។ អភិបាលកិច្ចឧស្សាហកម្មនិស្សារណកម្ម គឺសំដៅលើការបង្កើត និងអនុវត្តប្រកបដោយ

**តទៅទំព័រទី ៥**

**មតិយោបល់ទាំងឡាយដែលបានលើកឡើងនៅទីនេះជាទស្សនៈរបស់អ្នកនិពន្ធសុទ្ធសាធ មិនមែនជាទស្សនៈរបស់ម្ចាស់ជំនួយឡើយ**

Danida
HEINRICH BÖLL STIFTUNG CAMBODIA
MISEREOR DAS HILFSWERK
NORWEGIAN PEOPLE'S AID
Oxfam
TRÓCAIRE Working for a Just World

សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន
CAMBODIANS FOR RESOURCE REVENUE TRANSPARENCY

# CAMBODIANS FOR RESOURCE REVENUE TRANSPARENCY

Issue N⁰ 05 September 2010



*Photo: An abandoned mine field in Mondulkiri*

## New US Law Could be "Big Victory" for Transparency

*By Frank Yetter, CRRT Staff, from wire service reports*

Legislation signed into law last month by US President Barack Obama is being widely hailed by members of civil society as an important step towards improved transparency in the reporting of fees paid by public companies to non-US countries.

The law, crafted by US congressional committees led by US Sen. Christopher Dodd (D-Conn.) and US Rep. Barney Frank (D-Mass.), creates sweeping new regulations in consumer lending and banking in addition to the new requirements for companies to disclose payments made to non-US governments.

The measure was applauded in Cambodia by organizations working with the government to formulate policies of greater transparency, including Cambodians for Resource Revenue Transparency (CRRT).

"We believe that the disclosure of information from oil gas and mining companies will enable us to access information on revenues and will empower us to hold our government accountable for using oil revenues for economic development and basic social services like education and healthcare," said Mam Sambath, Chairman of CRRT.

